# សេចក្តីជូនដំណឹង

គម្រោងពិពិធកម្មកសិកម្មកម្ពុជានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណៈជនទាំងអស់មេត្តាជ្រាបថា គម្រោងពិពិធកម្មកសិកម្មកម្ពុជា (Cambodia Agricultural Sector Diversification Project)នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយអន្តរក្រសួងរួមមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម ក្រោម ហិរញ្ញប្បទានពីធនាគារពិភពលោក កំពុងបន្តផ្សព្វផ្សាយព័ត៌មានគម្រោងពិពិធកម្មកសិកម្មកម្ពុជា ដំណាក់កាលទី២ នៅតាមបណ្តាស្រុក/ឃុំនៃខេត្តគោលដៅចំនួន១២ រួមមាន៖ ខេត្តបាត់ដំបង សៀមរាប ព្រះវិហារ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ក្រចេះ ត្បូងឃ្មុំ កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កណ្តាល និងរាជធានីភ្នំពេញ **ចាប់ពីថ្ងៃទី២៦ ខែវិច្ឆិកា រហូតដល់ពាក់កណ្តាលខែធ្នូ ឆ្នាំ២០២០។**

ការផ្សព្វផ្សាយនេះរៀបចំឡើងក្នុងគោលបំណងដើម្បី ១)ផ្សព្វផ្សាយព័ត៌មានគម្រោងទៅសហគមន៍កសិកម្ម ក្រុមផលិត កសិធុរកិច្ចខ្នាតតូច និងមធ្យម អ្នកប្រមូលទិញផលិតផលកសិកម្ម អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធនៅក្នុងតំបន់គោលដៅ ២)ផ្សព្វផ្សាយព័ត៌មាននៃការគាំទ្រហិរញ្ញប្បទានរបស់គម្រោងពិពិធកម្មកសិកម្មកម្ពុជា រួមមាន ហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ (Matching Grant Facility) និងហិរញ្ញប្បទានឥណទានពីគ្រឹះស្ថានហិរញ្ញវត្ថុ (Credit Line) ៣) កំណត់អត្តសញ្ញាណសហគមន៍កសិកម្ម ក្រុមផលិត កសិធុរកិច្ចខ្នាតតូចនិងមធ្យម ដើម្បីរៀបសំណើធ្វើពិពិធកម្មកសិកម្ម និងផែនការអាជីវកម្មកសិកម្មដើម្បីទទួលបានការគាំទ្រហិរញ្ញប្បទានពីគម្រោងពិពិធកម្មកសិកម្ម និងគ្រឹះស្ថានហិរញ្ញវត្ថុដែលបានសហការ និង៤)ផ្សព្វផ្សាយព័ត៌មានកិច្ចគាំពារបរិស្ថាន និងសង្គម រួមទាំងលើកកម្ពស់យេនឌ័រ។

កម្មវិធីផ្សព្វផ្សាយនៅតាមស្រុករបស់ក្រុមការងារផ្តល់សេវាបច្ចេកទេសនៃ**អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍៖**

*១. ព្រឹកថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០២០ នៅសាលប្រជុំសាលាស្រុក ឱរ៉ាល់ ខេត្តកំពង់ស្ពឺ*
*២. ព្រឹកថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០២០ នៅសាលប្រជុំសាលាស្រុក ថ្ពង ខេត្តកំពង់ស្ពឺ*
*៣. ព្រឹកថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០២០ នៅសាលប្រជុំសាលាស្រុក ភ្នំស្រួច ខេត្តកំពង់ស្ពឺ*

សូមទំនាក់ទំនងព័ត៌មានបន្ថែមមកក្រុមការងារផ្តល់សេវាបច្ចេកទេស(Technical Service Provider) នៃ**អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍** និងស្នើសុំចុះឈ្មោះចូលរួមដោយឥតគិតថ្លៃក្នុងកម្មវិធីផ្សព្វផ្សាយទាំងនៅតាមបណ្តាស្រុកនៃខេត្តគោលដៅខាងលើ តាមរយៈទូរស័ព្ទ៖ 012 910 391/0967 211 168/ 012 442 016 /097 5611 101 ឬ Email: santhysimonba@gmail.com ។